

**ប្រតិកម្មរហ័ស**

# សេចក្ដីសង្ឃឹមខ្មែរ?

## L'espoir khmer ?

សេចក្ដីសង្ឃឹមមិនមែនថិតនៅលើការរកយុត្តិធម៌ តាមប្រព័ន្ធតុលាការ ឬ តាមគោលវិធីលទ្ធិប្រជាធិបតេយ្យនោះឡើយ ព្រោះនៅក្នុងស្រុកខ្មែរ វាគ្មានស្ថាប័នជាតិណាមួយ សំរាប់ធានាសេរីភាពប្រជាពលរដ្ឋនោះទេ។ ច្បាប់ទាំងឡាយ ដែលរាជរដ្ឋាភិបាលយកមកអនុវត្ត វាគ្មានសេចក្ដីទាក់ទងគ្នាបន្តិចសោះនឹងហេតុការ ដូចយ៉ាងការចាប់ឃុំឃាំងបេក្ខជនជាប់ឆ្នោតជាតំណាងរាស្ត្រ នៃគណបក្សសង្គ្រោះជាតិជាឧទាហរណ៏។ ទង្វើនេះ វាបញ្ជាក់ថា នៅស្រុកខ្មែរ វាគ្មាននីតិរដ្ឋ ដែលជាគ្រឿងសំរាប់ធ្វើឲមានប្រលូនល្អ (bon fonctionnement) នូវសមតានៃអំណាចនីតិបញ្ញាតិ, ប្រតិបត្ត និង តុលាការ ដែលជាគ្រិះនៃលទ្ធិប្រជាធិបតេយ្យ។ ទុកណា ពួកអ្នកជូនដំណឹង (communiquant) ជាផ្លូវការ ឬ ក្រៅផ្លូវការក្ដី ខំធ្វើការបកស្រាយ រកភាពការធ្វើត្រូវរបស់រាជរដ្ឋាភិបាល ក៏ការបកស្រាយទាំងនោះ មិនអាចមានភាពសមហេតុសមផល សំរាប់អ្នកយុត្តសាស្ត្រ និង អ្នកដែលមានសុភនិច្ឆ័យ បាននោះឡើយ។ អំពើខុសច្បាប់ ឬ រំលោភច្បាប់ជាពិសេសពីសំណាក់អ្នកកាន់អំណាចផ្ដាច់ការ នៅក្នុងប្រទេសគ្មាននីតិរដ្ឋ វាបង្ហាញរួចស្រេច នូវរូបអជ្ញាចារ (ការបំពាន) វាជាក់ស្ដែង ដូចក្លិនអាចម៏នោះឯង។

តែបើខ្មែរយើង ឬ គណបក្សប្រឆាំង(?) នៅតែមានជំនឿដោយសង្ឃឹមថា អាចនឹងកែឆ្នៃរបបផ្ដាច់ការនៅភ្នំពេញឲក្លាយជារបបលទ្ធិប្រជាធិបតេយ្យបាន នោះគឺពិតជាការសុបិនឥតចាំបាច់ដេក ឬ ជាការស្រមៃលលា (délire)។ អស់រយៈជិតមួយឆ្នាំហើយ គណបក្សប្រឆាំង(?)រស់នៅក្នុងការស្រមៃលលានេះ ឥតបានធ្វើអ្វីទាំងអស់ ក្រៅពីដើរពន្យល់រាស្ត្រឲធ្វើភាវនាធម៏សូមសន្តិភាព, នាំគ្នាច្រៀងបទជាតិសុំឲទេវតារក្សាព្រះមហាក្សត្រ នៅពេលបើកសម័យប្រជុំម្ដងៗ

និង ធ្វើការឃោសនាបោះឆ្នោតថ្នាក់ ឃុំស្រុកខេត្ត ទោះបីគ្មានការដូរ គ.ជ.ប.ក្តី ដែលខ្លួនទុកវាជា និមិត្តរូប នៃអកុសលផ្តាច់មុខ (le mal absolu) សំរាប់លទ្ធិប្រជាធិបតេយ្យ។ ការរកចងសំភារជាមួយពួកអ្នកកាន់អំណាចផ្តាច់ការ ជាយុទ្ធសាស្រ្តបិទទ្វារដោយខ្លួនឯង មិនអាចឲសហគមន៏អន្តរជាតិ មានលទ្ធភាពមានមតិក្តី ឬ អន្តរាគមន៏ដោយចំពោះមុខក្តី មិនចំពោះមុខក្តី ក្នុងបញ្ហានយោបាយខ្មែរ ព្រោះគេពុំអាចបំពានលើឆន្ទៈភាគីជម្លោះខ្មែរបាននោះឡើយ។ យុទ្ធសាស្រ្តភន្តច្រឡំ ឬ នយោបាយជាពនេចរ (aventure) របស់គណបក្សប្រឆាំង(?) នេះ ជាអាវុធវាយកំទេច ម្តងទៀតនៃជនាកម្លាំង (force populaire) ដែលកើតឡើងដោយឯងឯង (សយម្ភូត) ដោយសារប្រជាជនឥតអាចទ្រាំរស់ក្នុងទុក៍តភាព និង អយុត្តិធម៌ ជានិច្ចនិរន្តក្នុងសង្គមខ្មែរ។ ការបំផ្លាញជនាកម្លាំង ម្តងៗ នាំឲប្រជាពលរដ្ឋបាត់ដៅចំណាំនៃគ្រិះកម្លាំងរបស់ខ្លួន ដែលមានប្រភពក្នុងព្រលឹងជាតិ។ គ្រិះកម្លាំងនោះគឺមាន គោលការណ៏សំខាន់ដូចតទៅះ ខ្លួនទីពឹងខ្លួន,សេចក្តីក្លាហាន, យល់ត្រូវ, គ្រិះរិះត្រូវ, និយាយត្រូវ, ការងារត្រូវ។ ទោះបីយ៉ាងណា របបចោរម័ត (Kleptocratie) នៅភ្នំពេញ ពុំអាចឆ្លៀតទាញគុណប្រយោជន៏ពី ភាពស្រយុតប្រាជ្ញា (défaillance d’intelligence) របស់អ្នកដឹកនាំគណបក្សសង្រ្គោះជាតិ(?) ព្រោះ គ្រប់អំណាចអវិជ្ជា តែងតែត្រូវកម្លាំងធម្មជាតិបោសសំអាត យកកន្លែងទុកឲកម្លាំងជឿនលឿនដុះ ដើម្បីសេចក្តីចំរើននៃមនុស្សជាតិ។ សន្តិភាពស្ថាពរពុំអាចមាន នៅក្នុងសង្គមមួយ ដែលគ្មាន យុត្តិធម៌, គ្មានសេរីភាព និង គ្មានសីលធម៌ ជាស្ដុំ (pilier) នៃសង្គម។ គួរ ហ៊ុនសែន ឈ្វេងយល់ថា អ្នកដែលខ្លាចអំណាចសាច់ដុំរបស់ខ្លួន មានតែ ស្តេចអាយ៉ង, រដ្ឋមន្រ្តីជាចោរលួចជាតិ, នាម៉ឺនមន្រ្តីពុករលួយ, ឈ្មួញទុចរិច្ច, ជនយកនយោបាយជាតិធ្វើជារបរចិញ្ចឹមជីវិត, អ្នកឆ្លៀតទាញគុណប្រយោជន៏ពីប្រជាពលរដ្ឋ តែប៉ុណ្ណោះទេ ឯចំណែកខ្មែរ អ្នកជា ជាសុជន គេគ្មានអារម្មណ៏អ្វី ត្រូវនាំគ្នាខ្លាចអំណាចបែបម៉ាវហ្វា (mafia) នោះទេ។ សម្បត្តិមហាសេដ្ឋី នៃក្រុមអ្នកកានអំណាច ជាហិរសម្បត្តិ (bien de la honte) មានម្ចាស់ទុចរិច្ច រកបាន ពីការកេងប្រវ័ញ្ចគ្រប់បែបយ៉ាងពី កេតនភ័ណ្ឌ (bien national) គឺវា ជាមហាទុក្ខរបស់ហ៊ុន-សែនគ្រប់ពេលវេលាដល់អវសាន ព្រោះអ្វីដែលជាអំពើអសីលធម៌ វាតែងលាប ស្រលាប ធ្វើឲសៅហ្មង ឲប្រឡាក់ ឲជំពាក់នូវសេចក្តីក្តៅក្រហាយពីណាក់ជនរងគ្រោះជានិច្ច ដែលជាឧបស័គ្គធម្មជាតិ មិនយូរមិនឆាប់ វាតែងតែ មានកម្លាំងយុត្តិធម៌ណាមួយ វាយរំលំវាបានជានិច្ច

ដូច្នេះ អំណាចសាច់ដុំ និង ហរិសម្បត្តិ វាជាវត្ថុអនិច្ច តែប៉ុណ្ណោះ ព្រោះវាឋិតនៅក្រោមច្បាប់ធម្មជាតិ។

តែប្រជាពលរដ្ឋពុំអាចដេកចាំច្បាប់ធម្មជាតិ ឲជាអ្នកសំរេចលើជោគវាសនារបស់ខ្លួននោះដែរ ព្រោះច្បាប់ធម្មជាតិខ្លះ វាមានលក្ខណៈមិនទៀងទាត់ក្នុងពេលវេលា តែមនុស្សអាចប្រើប្រាជ្ញាឲកើតបានក្នុងនិស្ស័យ (certitude) ដូចយ៉ាងអវសានយ៉ាងរហ័យនៃរបបផ្តាច់ការ គាង (au lieu de) នាំគ្នាអង្គុយចាំ អវសាននេះវាមកដល់ឯងឯង ព្រោះជួនកាលវាមកដល់ពិតមែន តែវាហួសពេលវេលាទៅហើយ។ និស្ស័យ (ការដាក់ច្បាស់) នៃព្រឹត្តិការណ៍នេះ គឺការធ្វើបដិវត្តន៍។ ក្នុងករណីខ្មែរ គឺប្រជាជនត្រូវនាំគ្នាធ្វើបដិវត្តអហឹង្សា តាមអធ្យប័ន (instruction) នៃចលនាបដិវត្តន៍ផ្កាឈូក ដែលយើងយល់ឃើញថាជាអំពើប្រាកដនិយមមួយដើម្បីវាយរំលំរបបផ្តាច់ការ។ តែអាចធ្វើបដិវត្តអហឹង្សានេះបាន លុះត្រាតែប្រជាជនខ្មែរ ធ្វើជានាងការសកម្មមានសេចក្តីក្លាហាន មានការប្តេជ្ញាចិត្តក្នុងគោលការណ៍ «ខ្លួនទីពឹងខ្លួន» នាំគ្នាលែងដេកចាំព្រះធម្មិក, សម-រង្ស៊ី, កឹម-សុខា ដែលសព្វថ្ងៃនេះ ក្លាយខ្លួនជាមនុស្ស ហ៊ុន-សែន និង ស-ខេង បាត់ទៅហើយ ព្រោះម្នាក់ៗគេដឹងច្បាស់ថាគេនឹងបានទទួលរង្វាន់អ្វីមួយច្បាស់ បើកាលណា ការចងសំភារ រវាងគណបក្សសង្គ្រោះជាតិ(?) និងគណបក្សប្រជាជន បានដល់គោលដៅពិតប្រាកដមែន។ ឧទាហរណ៍មាននៅក្នុងសេចក្តីថ្លែងការណ៍ដ៏កំសាកមួយ របស់ សម-រង្ស៊ីថ្មីៗនេះក្រោយពីមានការចាប់ឃុំឃាំងបេក្ខជនជាប់ឆ្នោតតំណាងរាស្ត្រ៧នាក់ នៃគណបក្សខ្លួនថា ខ្លួនចង់ឲមានការផ្សះផ្សាជាតិដើម្បីយកសន្តិភាព និង យុត្តិធម៌ជូនប្រជាពលរដ្ឋ ឲបន្តការចរចារជាមួយគណបក្សកាន់អំណាចដើម្បីទម្លុះភាពទាល់ច្រកនយោបាយដែលកំពុងជាប់គាំងសព្វថ្ងៃ។ សម-រង្ស៊ីសង្ឃឹមថា ការវិលត្រឡប់ចូលស្រុក ដែលបានគ្រោងទុកក្នុងថ្ងៃទី១៩កក្កដានេះ  នឹងជួយឲមានការដោះលែងបេក្ខជនតំណាងរាស្ត្រជាប់ឆ្នោតនិង សកម្មជនគណបក្សឲមានសេរីភាពឡើងវិញ(Sic)។ សម-រង្ស៊ី កំពុងចង់ដើរតួជាសពស្តេចសីហនុ គឺជាអ្នករកសុខឲគណបក្សកាន់អំណាច ក្នុងគោលការណ៍នយោបាយផ្សះផ្សាជាតិ ហាក់បីដូចនៅស្រុកខ្មែរកំពុងមានជម្លោះរវាងភាគីយុទ្ធការី មានសមតាកម្លាំង ច្បាំងគ្នាយកឈ្នះរៀងខ្លួន។ តាមពិតគឺជា ការបង្ក្រាបដោយអំពើហឹង្សាពីសំណាក់កងកម្លាំងរាជរដ្ឋាភិបាលឥតស្របច្បាប់ មកលើអ្នកប្រជាធិបេតយ្យឥតអាវុធសុទ្ធសាត ដើម្បីបំបិទសេរីភាពពលរដ្ឋ។ ផ្សះផ្សាជាតិដែលសម-

រង្សី ចង់បាននោះ គឺជាការកាត់ទោសរួចស្រេចដល់អ្នកប្រជាធិបតេយ្យ ថាជាអ្នកមានកំហុសដែរ ព្រោះមានអំពើហឹង្សាកើតមានឡើង តែសម-រង្សីភ្លេចគិតថា អំពើហឹង្សានោះ វាកើតឡើង ពីការបង្កហេតុពីសំណាក់កងប្រដាប់អាវុធ នៃរាជរដ្ឋាភិបាលនោះឡើយ។ ជាពិសេសទៅទៀត សម-រង្សី កំពុងទុកការចាប់ឃុំឃាំងលោកស្រីមូរ-សុខហួរ លោក ម៉ែន-សុថាវរិន្ទ្រ, កែវ-ភិរម្យ, ហូរ-វ៉ាន់, វៀល-ខេម, នុត-រំដួល, ឡុង-រី ជារឿងផ្សេងៗ (faits divers) ដែលមានកើតឡើងជាធម្មតាតែប៉ុណ្ណោះ ហើយអាចបំភ្លេចវាចោលបានយ៉ាងងាយបំផុត។ រួមសេចក្ដីមក សេចក្ដីថ្លែងការណ៍ របស់សម-រង្សី គឺជាសំដីបំបាំង ការសុំទោស ដល់ ហ៊ុន-សែន ដើម្បីសុំសុខដល់ខ្លួនតែប៉ុណ្ណោះ។ តើសង្ឃឹមខ្មែរ ជាសេចក្ដីសង្ឃឹមលើជនបែប សម-រង្សីនេះឬ? បើជាការពិតមែន យើងគួរអាសូរដល់ជនជាតិខ្មែរណាស់ !